**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៦៥៧ សហវ

**ប្រកាសអន្តរក្រសួង**

**ស្តីពី**

**ការអនុញ្ញាតឱ្យសេវាសុខាភិបាលអនុវត្ត**

**ការពិនិត្យ និងព្យាបាលជំងឺដោយ យកកំរៃខ្លះពីអ្នកជំងឺ**

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ ៥/សរកម/០៧០៤/០០១ ចុះថ្ងៃទី ១៣-០៧-២០០៤ ដែលប្រកាសអោយប្រើច្បាប់រដ្ឋធម្មនុញ្ញបន្ថែមសំរាប់ធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ ។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ចុះថ្ងៃទី ១៥-០៧-២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី ២៤-០១-៩៦ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល ។
- បានឃើញព្រះរាជក្រមលេខ នស/ រកម / ០១៩៦ / ១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ-បក ចុះថ្ងៃទី ២២-១០-៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល ។
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។
- អនុវត្តតាមសេចក្តីជូនដំណឹងលេខ ១២៨១ ស.ជ.ណ.អ.រ ចុះថ្ងៃទី ២២ ខែសីហា ឆ្នាំ១៩៩៥ របស់ទីស្តីការគណៈរដ្ឋមន្ត្រីស្តីពីការឯកភាពជាគោលការណ៍ ឱ្យមន្ទីរពេទ្យរដ្ឋ ថ្នាក់កណ្តាល ថ្នាក់ខេត្ត-ក្រុង និងថ្នាក់ស្រុក រៀបចំផ្នែកពិនិត្យ និង ព្យាបាលជំងឺយកកំរៃពីអ្នកជំងឺខ្លះ ។

## សំរេច

**ប្រការ ១ :** ត្រូវបានអនុញ្ញាតឱ្យផ្នែកសេវាសុខាភិបាល រៀបចំការបង្កើតការពិនិត្យ និង ព្យាបាលជំងឺ យកកំរៃពីអ្នកជំងឺ តាមមន្ទីរពេទ្យថ្នាក់កណ្តាល មន្ទីរពេទ្យបង្អែកខេត្ត-ស្រុក និង មណ្ឌលសុខភាព ។

**ប្រការ ២ :** សេវាដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តតាមគោលនយោបាយសុខាភិបាល ដោយត្រូវយកចិត្តទុកដាក់ថែទាំអ្នកជំងឺ គោរពសីលធម៌ វិជ្ជាជីវៈ ក្នុងស្មារតី មនុស្សធម៌ ទូលំទូលាយ រក្សាបាននូវគុណភាពសេវា និង មិនយកថ្លៃពីអ្នកជំងឺក្រីក្រ ។

**ប្រការ ៣ :** ការកំណត់កំរិតកំរៃដែលត្រូវយកពីអ្នកជំងឺ អាស្រ័យដោយគណៈកម្មការមួយដែលមានតំណាងក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ តំណាងក្រសួងសុខាភិបាល និង អង្គភាព រៀបចំដោយរដ្ឋមន្ត្រីក្រសួងសុខាភិបាល សំរាប់អង្គភាពថ្នាក់កណ្តាល ។

ចំពោះអង្គភាពខេត្ត-ក្រុង ស្រុក និង មណ្ឌលសុខភាព អាស្រ័យដោយគណៈកម្មការមួយដែលមានតំណាងសហគមន៍ តំណាងមន្ទីរហិរញ្ញវត្ថុ និង ប្រធានសាមីអង្គភាព រៀបចំដោយមន្ទីរសុខាភិបាលខេត្ត-ក្រុង រឺ គណៈកម្មការអភិវឌ្ឍន៍ស្រុក ឃុំ ។

**ប្រការ ៤ :** ថវិកាដែលប្រមូលបានពីអ្នកជំងឺ ត្រូវគ្រប់គ្រង និង ចាត់ចែងដូចខាងក្រោមនេះ :

- ៣៩% សំរាប់ជំនួយបង្កើនគុណភាពសេវាកម្ម
- ៦០% សំរាប់ចំណាយឧបត្ថម្ភមន្ត្រីរាជការ និយោជិក
- ១ % សំរាប់បង់ចូលថវិកាជាតិ ។

ដោយឡែកចំណូលផ្សេងៗទៀតក្រៅពីចំណូលខាងលើត្រូវបង់ចូលថវិការដ្ឋ ៧៥% និង ២៥% សំរាប់ជំនួយបង្កើនគុណភាពសេវាកម្ម ។

**ប្រការ ៥ :** ដើម្បីឱ្យមានតម្លាភាពក្នុងការប្រើប្រាស់ប្រាក់ចំណូលនេះ គណៈកម្មាការហិរញ្ញប្បទាននិងអង្គភាព ត្រូវធ្វើរបាយការណ៍ចំណូលចំណាយ ជូនក្រសួងសុខាភិបាល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អោយបានជាប្រចាំរៀងរាល់ ត្រីមាស និងប្រចាំឆ្នាំ ។

**ប្រការ ៦ :** បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៧ :** អគ្គនាយករដ្ឋបាលហិរញ្ញវត្ថុ នាយកខុទ្ទកាល័យក្រសួងសុខាភិបាល អគ្គនាយកបច្ចេកទេសសុខាភិបាលប្រធានមន្ទីរសុខាភិបាលខេត្ត-ក្រុង ប្រធានមន្ទីរពេទ្យជាតិ មន្ទីរពេទ្យបង្អែក ប្រធានមណ្ឌលសុខភាព អង្គភាពពាក់ពន្ធ័ទាំងអស់ដែលស្ថិតក្រោមឱវាទក្រសួងសុខាភិបាល និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានភារៈកិច្ចទទួលបន្ទុកអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី១១ ខែតុលា ឆ្នាំ ២០០៥

រដ្ឋមន្ត្រីក្រសួងសុខាភិបាល

បណ្ឌិត. នុត-សុខុម

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត់ ចន់ វិបុល

ចំលងជូន :

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន
- គ្រប់សាលាខេត្ត-ក្រុង

  " ដើម្បីជូនជ្រាប "
- ដូចប្រការ៧ " ដើម្បីអនុវត្ត "
- ឯកសារ និង កាលប្បវត្តិ